ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៩-១២-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៥ តែងតាំងឯកឧត្តម **គាន់ មឿន** ទីប្រឹក្សាសម្តេចក្រុមព្រះប្រធានរដ្ឋសភា | ១៩១៧ |
| ១២-១២-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៦ តែងតាំងឯកឧត្តម នុត សុខុម ជាអនុប្រធានប្រចាំការអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ | ១៩១៧ |
| ១២-១២-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៧ តម្លើងឋានន្តរសក្តិជូនលោក វរសេនីយ៍ឯក តាន់ បញ្ញារុធ ជំនួយការសម្តេចនាយករដ្ឋមន្ត្រី ជាឧត្តមសេនីយ៍ត្រី នៃនគរបាលជាតិ | ១៩១៨ |
| ១៥-១២-២០០០ | -ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៨ តែងតាំង លោក **លឹម ម៉ិនសួរ** ជាឧកញ៉ា | ១៩២០ |


## II- រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី | ១៩២១ |
| ១៥-១២-២០០០ | -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពីការលុបឡូត៍នេសាទ និង កាត់បន្ថយដែននេសាទក្នុងនាទីឡូត៍ នេសាទ ខេត្តបាត់ដំបង ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ | ១៩២៦ |
| ១៥-១២-២០០០ | -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៩២៨ |
| ១២-១២-២០០០ | -អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្តីពីការតែងតាំង មន្ត្រីរាជការ | ១៩២៩ |
| ១២-១២-២០០០ | -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣០ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣១ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣២ |

| | | |
|---|---|---|
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣៣ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣៤ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣៤ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣៥ |
| ១៣-១២-២០០០ | -អនុក្រឹត្យលេខ ៩១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៣៦ |

## III- ការងារបណ្ណាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

#### ប្រកាស

| | | |
|---|---|---|
| ១៤-១២-២០០០ | -ប្រកាសលេខ ១០២២ ឧរថកឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ថៃយ៉ា ហ្វាមេន អ៊ិនដាសស្ត្រី តំណាងដោយលោកស្រី JANG YEN FAN សញ្ជាតិចិន ( តៃវ៉ាន់) បង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់នាំចេញ | ១៩៣៧ |

### ២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

#### ប្រកាស

| | | |
|---|---|---|
| ១៤-១២-២០០០ | -ប្រកាសលេខ ១១៥៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " រុងរឿង " ក្នុងឃុំរុងរឿង ស្រុកស្ទោង ខេត្ត កំពង់ធំ | ១៩៣៩ |
| ១៤-១២-២០០០ | -ប្រកាសលេខ ១១៦០ អយក. ប្រក ស្តីពីការបើកអនុវិទ្យាល័យ "សំរោងក្នុង" ក្នុងឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង | ១៩៤០ |
| ១៤-១២-២០០០ | -ប្រកាសលេខ ១១៦២ អយក.ប្រក ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ "ថ្មល់បំបែក" ទៅជាវិទ្យាល័យ សុខ អាន " ថ្មល់បំបែក " | ១៩៤១ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានព្រះរាជាណាចក្រកម្ពុជា លេខ ១០១៤ រស ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០០

ត្រាស់បង្គាប់

មាត្រា ១._ តែងតាំងឯកឧត្តម តាន់ ម្យៀន ជាទីប្រឹក្សាសម្តេចក្រុមព្រះប្រធានរដ្ឋសភា មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២._ ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០០
ព្រះហស្តលេខា
នរោត្តម សីហនុ

★★★

### ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ ស្ដីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង និងជំងឺអេដស៍
- យោងតាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាលេខ ១៩៣ លស ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០

**ត្រាស់បង្គាប់**

**មាត្រា ១.** តែងតាំងឯកឧត្ដម **នុត សុខុម** ជាអនុប្រធានប្រចាំការអាជ្ញាធរជាតិប្រយុទ្ធ នឹងជម្ងឺអេដស៍ ជំនួសឯកឧត្ដម **ឌី ណារ៉ុមរិទ្ធ** ។

**មាត្រា ២.** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

**មាត្រា ៣.** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០

ព្រះហស្ដលេខា

**នរោត្ដម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/១២០០/២១៧**

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់បរស់សំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០០

## ត្រាស់បង្គាប់

មាត្រា ១._ ត្រូវបានតំឡើងឋានន្តរសក្តិជូនលោកវរសេនីយឯក តាន់ បញ្ញាឧុធ អត្តលេខ ០៣៩៨ ជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា ជា ឧត្តមសេនីយ៍ត្រី នៃនគរបាលជាតិ ។

មាត្រា ២._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកព្រះរាជក្រឹត្យនេះ ឲ្យបានសំរេច ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យ លេខ នស/រកត/១១០០/២១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក លឹម ម៉ុនសួរ

ជា

ឧកញ៉ា

ធ្វើនៅព្រះបរមរាជវាំង ភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

### អនុក្រឹត្យលេខ ៩៦ អនក្រ.បក

### ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់
### អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១០០/២១៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

### សំរេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអង្គភាពនានារបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

### ជំពូកទី ២

### តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

មាត្រា ៣._

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មដាក់អោយដំណើរការ កម្មវិធីការងារដីធ្លីតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ :

១- រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ។

២- ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ លើគោលនយោបាយដីធ្លី ។

៣- លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសំរេច ។

៤- លើកគំរោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លីដាក់អោយដំណើរការអនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ ។

៥- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយប្រើប្រាស់ដីឲ្យបានសមស្រប និងមានសមធម៌ ។

៦- ជំរុញការចុះបញ្ជីដីធ្លី ជាប្រព័ន្ធទូទាំងប្រទេស ។

៧- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុ ជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យមានប្រសិទ្ធភាព ។

៨- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឲ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់ ។

៩- ធ្វើទំនាក់ទំនងដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ដើម្បីបំពេញការងារ ។

១០- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឲ្យបានគ្រប់គ្រាន់ ដើម្បីដំណើការការងារដីធ្លី ។

១១- លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

១២- លើផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

១៣- ជំរុញតាមដាន វាយតំលៃលើគំរោងការងារដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារ ។

មាត្រា ៤._

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

មាត្រា ៥._

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សានយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញការងាររបស់ខ្លួន ។

មាត្រា ៦._

អគ្គលេខាធិការ មានសិទ្ធលើកសំណើជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិនិត្យ និងសំរេចលើសេចក្តីប្រកាសតែងតាំង ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៧._

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ក្រុមការងារនយោបាយ និងគតិយុត្ត

២- ក្រុមការងារបច្ចេកទេស

៣- ក្រុមការងារពង្រឹងស្ថាប័ន

៤- ក្រុមការងាររដ្ឋបាល

ក្រុមការងារនីមួយៗត្រូវបានដឹកនាំនិងគ្រប់គ្រងដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៨._

ការបែងចែកលំអិតនៃភារកិច្ចបុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ៩._

ក្រុមការងារនយោបាយនិងគតិយុត្ត មានភារកិច្ច ៖

- រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ
- ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី លើគោលនយោបាយដីធ្លី
- លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាកំណែទំរង់ដីធ្លីដើម្បីពិនិត្យ និងសំរេច

- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយប្រើប្រាស់ដីធ្លីឲ្យបានសមស្រប និងមានសមធម៌
- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឲ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់
- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឲ្យបានគ្រប់គ្រាន់ ដើម្បីដំណើរការការងារដីធ្លី
- លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

**មាត្រា ១០.-**

ក្រុមការងារបច្ចេកទេស មានភារកិច្ច ៖

- លើកគំរោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លី ដាក់ឲ្យដំណើរការអនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ
- ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធទូទាំងប្រទេស
- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដីលើអចលនវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋឲ្យមានប្រសិទ្ធភាព ។

**មាត្រា ១១.-**

ក្រុមការងារពង្រឹងស្ថាប័ន មានភារកិច្ច ៖

- ទំនាក់ទំនងដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ ដើម្បីបំពេញការងារ
- លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅជាពិសេសការងារដីធ្លី
- ពង្រឹងគណៈកម្មការដោះស្រាយបាតុភាពបញ្ហាទំនាស់ដីធ្លី ។

**មាត្រា ១២.-**

ក្រុមការងាររដ្ឋបាល មានភារកិច្ច ៖

- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- កសាងគំរោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តន៍ថវិកា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំ និងសំរួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន

- តាមដានវាយតំលៃលើគំរោងការងារដីធ្លីដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីលទ្ធផលការងារនេះ ។

មាត្រា ១៣._

អគ្គលេខាធិការដ្ឋានប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា លក្ខខ័ណ្ឌនៃពេភការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ ពិសេសសំរាប់បើកជូនភ្នាក់ងារនៃមុខងារសាធារណៈ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមសំណើរបស់អគ្គលេខាធិការ ។

មាត្រា ១៤._

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្តល់មកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

មាត្រា ១៥._

ការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចាប់ពីក្រោមថ្នាក់ប្រធាននាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណូមពររបស់អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

មាត្រា ១៦._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧._

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន និងសមាជិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

ហត្ថលេខា

**អ៊ឹម ឈុនលឹម**

★★★

# អនុក្រឹត្យលេខ ៩៧ អនក្រ.បក

## ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តបាត់ដំបង ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី០៩ ខែមិនា ឆ្នាំ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧/អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបនិងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១.-** ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសរក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាបក្នុងខេត្តបាត់ដំបង ដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទលេខ ០៣ លេខ ០៥ និងលេខ ០៧ ចាប់ពីរដូវនេសាទ ២០០១ ២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តបាត់ដំបង និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មីចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយនេះ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្ត បាត់ដំបងដែលត្រូវកាត់បន្ថយ

ឯកតា ហិកតា

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍នេសាទ | ផ្ទៃឡូត៍កាត់ចេញ | ផ្ទៃឡូត៍កាត់ចេញ គិតជាភាគរយ | ផ្ទៃឡូត៍នេសាទ នៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ១១.៦១៥ | ៤៨៥ | ៤.១៧ | ១១.១៣០ | |
| ២ | ៥០.៦២៥ | ៤៩០ | ០.៩៧ | ៥០.១៣៥ | |
| ៣ | ៩.១៩៨ | ៩.១៩៨ | ១០០ | ០ | លប់ចេញ |
| ៤ | ១៣.៨៨៣ | ២.១៥៦ | ១៥.៥៣ | ១១.៧២៧ | |
| ៥ | ៣.៦៥៦ | ៣.៦៥៦ | ១០០ | ០ | លប់ចេញ |
| ៦ | ១២.០៣៩ | ២.០០៣ | ១៦.៦៥ | ១០.០៣៦ | |
| ៧ | ១១.២៥១ | ១១.២៥១ | ១០០ | ០ | លប់ចេញ |
| ៨ | ១៥.២៦៨ | ៨.២៩៦ | ៥៨.១៥ | ៥.៩៧២ | |
| ៩ | ៤.៧៨៤ | ៥៩៣ | ១២.៤០ | ៤.១៩១ | |
| ១០ | ២.៧៧៧ | ៣២១ | ១១.៥៦ | ២.៤៥៦ | |
| ១១ | ៧.៨៩៥ | ៣.៣៥០ | ៤២.៥៥ | ៤.៥៤៥ | |
| ១២ | ៤.៥៥៤ | ២.០២៦ | ៤៤.៤៩ | ២.៥២៨ | |
| សរុប ១២ | ១៥៦.៥៣២ | ៤៣.៨១៥ | ២៩.៩០ | ១០២.៧១៨ | |

មាត្រា ២.- ដែននេសាទដែលបានលប់ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារហាមដាច់ខាតមិនអោយជនណាមួយ ហ៊ុងហែងយកទៅលក់ ឬជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

មាត្រា ៣.- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទដើម្បីគ្រប់គ្រងកន្លែងដែលបានលប់និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

មាត្រា ៤.- រាល់បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនិងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អភិបាលខេត្ត

បាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៨ អនក្រ.បក

## ស្ដីពីការផ្ទេរឥណទានថវិកា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦៨.៨៥១.០០០ រៀល (ហុកសិបប្រាំបី លានប្រាំបីរយហាសិបមួយពាន់រៀល) ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) មកជំពូក៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ : វិភាគទានអោយអង្គការអន្តរជាតិនានា) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ។

មាត្រា ២._ ផលពាណិជ្ជកម្ម ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់ចំណាយបង់វិភាគទានជូនអង្គការ FAO & CITES ។

មាត្រា ៣._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៤០៨ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះអនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

### សំរេច

មាត្រា ១._ ត្រូវបានតែងតាំងលោក **តាន់ មញ្ញាទុធ** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ទទួលការងារនគរបាល មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

អនុក្រឹត្យលេខ ៨០៩ អនក្រ.តត

**ជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការ ប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

**សំរេច**

មាត្រា ១._ ត្រូវបាន ប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសំណង់ផ្សេងៗ នៅវត្តទួលសាលា ក្នុងឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចជាព្រះវិហារ សាលារៀន សាលាបាលី កុដិព្រះសង្ឃ ផ្លូវលំ ក្លោងទ្វារ របងវត្ត ។ល។ ដូចមាននាមខាងក្រោមនេះ :

១-លោក **សូ ខួន** នាយកក្រុមហ៊ុន "សូ ងួន ដឹកជញ្ជូន សេវា អាហ័រណ-នីហ័រណ"

ទឹកប្រាក់ ១២២.៩១២.១០ ដុល្លារអាមេរិក

២-លោក **សូ សុវណ្ណ** នាយកក្រុមហ៊ុន "សូ សុវណ្ណ អាហ័រណ-នីហ័រណ និងដឹកជញ្ជូន"

ទឹកប្រាក់ ១២២.១៧៤.៦០ ដុល្លារអាមេរិក

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បត្តបេខា និងត្រា

ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៨១០ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកតា **ម៉ីខ ហ៊ិន** ជនជាតិខ្មែរ រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធាន ជួយកសាងសំណង់ផ្សេងៗ នៅតាមវត្តចំនួន ០៨ ក្នុងស្រុកកំពង់ត្រាច និងស្រុកកំពង់បាយ ខេត្តកំពត ចំណាយអស់ទឹកប្រាក់សរុបចំនួន ២៦៧.៩៥៥ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៤១១ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពី ការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ០២រូប ដែល បានជួយកសាងអាគារសិក្សា ០១ខ្នង មាន០៦បន្ទប់ ដោយបំពាក់សម្ភារៈសិក្សាគ្រប់បន្ទប់ នៅអនុវិទ្យា- ល័យភ្នំស្រុក ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ចំនួន ២៣.០០០ ដុល្លារអាមេរិក ដូចមាន រាយនាមខាងក្រោមនេះ ៖

១-លោក **ខាង ឃឿង**

២-អ្នកស្រី **ចៅ ឈីទ**

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩១២ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះគ្រូសាក្យវង្ស ព្រះមង្គលទិព្វលោករង្សី ជ៉ាន់ សូស្តី ព្រះរាជាគណៈថ្នាក់ត្រី ព្រះមេគណខេត្តតាកែវ ដែលបានបរិច្ចាគថវិកាផ្ទាល់ព្រះអង្គចំនួន ១៩.៥៤០ ដុល្លារអាមេរិក សំរាប់ចូលរួមកសាងអាគារសិក្សានៅក្នុងបរិវេណវិទ្យាល័យ ហេង សំរិន ព្រៃល្វា រួមនឹងសំណង់ផ្សេងៗទៀតក្នុងវត្តព្រៃល្វា ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

# អនុក្រឹត្យលេខ ៩១៣ អនក្រ.តត
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តតាកែវ

## សំរេច

មាត្រា ១._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក ម៉ៅ ញ៉ន និងលោកស្រី ឆាន សារឹម ជាភរិយា ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសាលារៀន ស្ពាន ផ្លូវលំ វត្តអារាម និងសំណង់ផ្សេងៗ នៅក្នុងទឹកដីខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន ៥៩.៧៩១.៦០០ រៀល ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ៩១៤ អនក្រ.តត
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

**សំរេច**

មាត្រា ១._ ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** ជូនអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដែលបានផ្តល់ថវិកាសំរាប់កសាងអាគារសិក្សា នៅសាលាបឋមសិក្សាគុតពាំងវែង ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានឈ្មោះខាងក្រោម ៖

**ក- មេដាយមាសស្ថាបនាជាតិ**

១-អង្គការ CHILD ACADEMY KAMIYA SHIRO ឧបត្ថម្ភថវិកា ចំនួន ១២.000 USD

២-អង្គការ NAGOYA INTERNATIONAL PRESCHOOL ឧបត្ថម្ភថវិកាចំនួន ១១.៣00 USD

**ខ- មេដាយប្រាក់ស្ថាបនាជាតិ**

-អង្គការទស្សនពិភពលោក អន្តរជាតិកម្ពុជា ឧត្ថម្ភថវិកាចំនួន ៥.១៨0 USD

**មាត្រា ២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

***

**អនុក្រឹត្យលេខ ៤១៥ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនឧបាសិកា លុក សិ រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអាគារសិក្សាមួយខ្នង និងបង្គន់អនាម័យ ០៣ បន្ទប់នៅសាលាបឋមសិក្សាពោធិអណ្តែត ក្នុងភូមិពោធិកណ្តាល ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ចំណាយអស់ថវិកា ចំនួន ២០.០០០ ដុល្លារអាមេរិក ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩១៦ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់សមាគមឥស្លាមកម្ពុជា

សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៣ រូប នៅសហភាពអារ៉ាប់ អេមីរ៉ាត ដែលបានរួមគ្នាបរិច្ចាគថវិកាជួយកសាងវិហារឥស្លាម និងសាលារៀននៅភូមិវិហារសំបួរ ក្នុងឃុំកោះប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់ចំនួន ៣៥.០០០ ដុល្លារអាមេរិក ដូចមាននាមខាងក្រោម :

១- Mr. EISA BIN NASSER

១- Dr. MAHMOOD KAZIM

២- Dr. AHMED ALHASAEMY

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## III- ការងារបណ្តាក្រសួង

### ១- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០

**ប្រកាសលេខ ១០២២ ឧរថក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញលិខិតលេខ ៣២២៥/០០ គ.វ.ក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៣១៨ ប.ស្ថ សណ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខ ៣៥១ លអ ចុះថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ របស់សាលាខេត្តកណ្ដាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ថៃ យ៉ា ហ្គាមេន អ៊ិនដាសស្រ្ទី ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០

**សំរេច**

ប្រការ ១ ៖ អនុញ្ញាតអោយក្រុមហ៊ុន ថៃ យ៉ា ហ្គាមេន អ៊ិនដាសស្រ្ទី ( TAI YAR GARMENT INDUSTRY Co., LTD ) តំណាងដោយលោកស្រី JANG YEN FAN សញ្ជាតិ ចិន ( តៃវ៉ាន់ ) ភេទស្រី អាយុ ៣៩ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ ១២៨៧៣២២ ចុះថ្ងៃទី ០១-១០-១៩៩៦ បង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់នាំចេញ ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ ថៃ យ៉ា ហ្គាមេន អ៊ិនដាសស្រ្ទី " មានទីតាំងស្ថិតនៅផ្លូវជាតិលេខ ៥ ភូមិពោធិមង្គល ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្ដាល ។

ប្រការ ២ ៖ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ ៖ រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ -ដេរសំលៀកបំពាក់ " ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ ៖ ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៥ ៖ រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ ៖ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ ៧ ៖ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ ៖ អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកណ្ដាល និង ប្រធានក្រុមហ៊ុន ថៃ យ៉ា ហ្គាមេន អ៊ិនដាសស្រ្ទី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ ៖ ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស៊ុយ សែម

★★★

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០០

ប្រកាសលេខ ១១៥៩ អយក.ប្រក

ស្តីពីការបើក អនុវិទ្យាល័យ " រុងរឿង " ក្នុងឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ

***

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ឃុំរុងរឿង ស្រុកស្ទោង ខេត្តកំពង់ធំ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ធំ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

សំរេច

ប្រការ ១ ៖ អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា ៖ អនុវិទ្យាល័យ " រុងរឿង " ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ធំ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

***

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០០

## ប្រកាសលេខ ១១៦០ អយក.ប្រក
## ស្តីពីការបើក អនុវិទ្យាល័យ " សំពោចក្នុង " ក្នុងឃុំសំពោច ក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត២

- យោងលិខិតស្នើសុំរបស់នាយកអនុវិទ្យាល័យសំរោងក្នុងលេខ ៣៣ ស.រ.ក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត បាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " សំរោងក្នុង " ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តបាត់ដំបង និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

**រដ្ឋលេខាធិការ**

**ហត្ថលេខា និងត្រា**

**អ៊ឹម សិទ្ធី**

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០០

## ប្រកាសលេខ ១១៦២ អយក.ប្រក

## ស្តីពីការប្តូរឈ្មោះ វិទ្យាល័យ " ថ្នល់បំបែក " ទៅជាវិទ្យាល័យ សុខ អាន " ថ្នល់បំបែក " ស្ថិតនៅក្នុងឃុំជីខ្មារ ស្រុកទ្រាំង ខេត្ត តាកែវ

***

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតស្នើសុំលេខរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ លេខ ៤១២៥ អយក.ត.មចស ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពី អភិបាលខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យ "ថ្នល់បំបែក" បច្ចុប្បន្នទៅជាវិទ្យាល័យ ស៊ុខ អាន "ថ្នល់បំបែក" ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជន និងកីឡា ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
អ៊ឹម សិទ្ធី

***